ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៥១ មស.វបក

# របាយការណ៍
# បូកសរុបការងារប្រចាំឆ្នាំ២០១៧
# និងទិសដៅឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៥នៃរដ្ឋសភា បានបង្កើតក្រសួងមុខងារសាធារណៈ និង ប្រគល់ភារកិច្ចឱ្យបំពេញមុខងារនិងបេសកកម្មសំខាន់ក្នុងការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងការងារកែទម្រង់រដ្ឋបាលសាធារណៈ។

ក្នុងរយៈពេលមួយឆ្នាំ នៃការអនុវត្តមុខងារនិងបេសកកម្មរបស់ខ្លួន ក្រសួងមុខងារសាធារណៈបានប្រកាន់ខ្ជាប់នូវភាពជាម្ចាស់និងភាពដឹកនាំឈរលើអភិក្រមបុរេសកម្មចំពោះការងារ ដោយបានសហការយ៉ាងល្អជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមជាមួយបណ្តាដៃគូអភិវឌ្ឍន៍ក្នុងស្មារតីនៃការប្រមូលផ្តុំរួមគ្នានូវសមត្ថភាព បញ្ញាញាណ ធនធានសម្ភារៈ និងថវិកា ហើយសម្រេចបានសមិទ្ធផលយ៉ាងច្រើនជាប្រយោជន៍ដល់មន្ត្រីរាជការ ការរៀបចំ និងពង្រឹងសមត្ថភាពស្ថាប័ន ព្រមទាំងការកែលម្អសេវាសាធារណៈឱ្យកាន់តែល្អប្រសើរឡើង។

សមិទ្ធផលសំខាន់ៗដែលក្រសួងមុខងារសាធារណៈសម្រេចបានក្នុងឆ្នាំ២០១៧ មានដូចខាងក្រោម៖

## I- សកម្មភាពថ្នាក់ដឹកនាំ

ថ្នាក់ដឹកនាំក្រសួងបានអញ្ជើញចូលរួមកិច្ចប្រជុំ ការងារសង្គម និងពិធីផ្សេងៗ រួមមាន (១)អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី (២)ចូលរួមនិងដឹកនាំអង្គប្រជុំអន្តរក្រសួង (៣)ចូលរួមវេទិកាសាធារណៈទៅតាមមុខសញ្ញាកំណត់ (៤)ចូលរួមសិក្ខាសាលាស្តីពីការកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ (៦)អង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និង លើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ (៧)បានដាក់សម្ពោធឱ្យប្រើប្រាស់អាគាររដ្ឋបាលមន្ទីរមុខងារសាធារណៈខេត្តកោះកុង ខេត្តឧត្តរមានជ័យ ខេត្តកំពង់ចាម (៨)ពិធីប្រកាសចូលកាន់មុខតំណែងប្រធានមន្ទីរមុខងារសាធារណៈខេត្តតាកែវ និង ខេត្តបាត់ដំបង (១០)ពិធីចែកវិញ្ញាបនបត្រជូនដល់សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មីឆ្នាំ២០១៦របស់ក្រសួង ស្ថាប័ននានា នៅសាលាភូមិន្ទរដ្ឋបាល (១១)ចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន (១២)សិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង នីតិវិធីនៃការអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា នៃក្រសួងមុខងារសាធារណៈ នៅខេត្តព្រះសីហនុ និង (១៣)ចូលរួមកម្មវិធីនានាតាមការអញ្ជើញរបស់គណៈកម្មាធិការរៀបចំបុណ្យជាតិនិងអន្តរជាតិ ព្រមទាំងក្រសួង ស្ថាប័ននានា។

បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនិងសន្និសីទអន្តរជាតិសំខាន់ៗ រួមមាន (១)កិច្ចប្រជុំកំពូលរដ្ឋាភិបាលពិភពលោកប្រចាំឆ្នាំលើកទី៥ នៅប្រទេស United Arab Emirates (២)សន្និសីទ Civil Service International Conference នៅប្រទេសថៃ និង (៣)សន្និសីទ Eastern Regional Organization for Public Administration លើប្រធានបទ The Role of Public Governance in Achieving the Sustainable Development Goals: Transforming, Empowering, and Network Building នៅប្រទេសកូរ៉េ។

## II- សកម្មភាពជំនាញ

### ១- អង្គភាពថ្នាក់ជាតិ

#### ១.១- ការងាររដ្ឋបាល

- ក្រសួងបានទទួលលិខិតចូលចំនួន៩៥១១លិខិត និង លិខិតចេញចំនួន៤៨៨១លិខិត និងរៀបចំកិច្ចប្រជុំចំនួន៥០៦លើកដែលមានសមាជិកចូលរួមចំនួន១៥០៦៣នាក់

- បានរៀបចំវគ្គបណ្តុះបណ្តាលនិងដាក់ឱ្យអនុវត្តជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងចរន្តឯកសារ (File Tracking System) នៅក្នុងក្រសួងមុខងារសាធារណៈ និងកំពុងធ្វើបច្ចុប្បន្នភាពប្រព័ន្ធនេះ ដើម្បីដាក់ឱ្យដំណើរការនៅមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត។

១.២- <u>ការងារគ្រប់គ្រងបុគ្គលិក</u>

ក- <u>ការគ្រប់គ្រងស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការ</u>

- គិតត្រឹមខែធ្នូ ឆ្នាំ២០១៧ ក្រសួងមានមន្ត្រីរាជការសរុបចំនួន៨០៩នាក់/ស្ត្រី២៥៥នាក់ (ថ្នាក់កណ្តាលសរុបចំនួន ៤៩៤នាក់/ស្ត្រី១៥០នាក់និងថ្នាក់ក្រោមជាតិចំនួន៣១៥នាក់/ស្ត្រី១០៥នាក់) និង មន្ត្រីជាប់កិច្ចសន្យានៅថ្នាក់កណ្តាលសរុបមានចំនួន១៧៣នាក់និងថ្នាក់ក្រោមជាតិចំនួន១២៥នាក់
- ចំនួនមន្ត្រីរាជការកាន់មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនិងឋានៈស្មើ (១)រដ្ឋមន្ត្រីចំនួន០១នាក់ (២) រដ្ឋលេខាធិការនិងឋានៈស្មើរដ្ឋលេខាធិការចំនួន០៦នាក់/ស្ត្រី០៤នាក់ (៣)អនុរដ្ឋលេខាធិការនិងឋានៈស្មើអនុរដ្ឋលេខាធិការចំនួន១៦នាក់/ស្ត្រី០៤នាក់ (៤)អគ្គនាយកចំនួន០៣នាក់ (៥)អគ្គនាយករងចំនួន១៨នាក់/ស្ត្រី០៤នាក់ (៦)អគ្គលេខាធិការរងចំនួន០១នាក់ (៧)អគ្គាធិការចំនួន០១នាក់ (៨)អគ្គាធិការរងចំនួន០៥នាក់/ស្ត្រី០១នាក់ (៩)អធិការចំនួន០៧នាក់ (១០)ប្រធាននាយកដ្ឋានចំនួន១៧នាក់/ស្ត្រី០២នាក់ (១១) ប្រធានអង្គភាពលទ្ធកម្មចំនួន០១នាក់ (១២)អនុប្រធាននាយកដ្ឋាននិងឋានៈស្មើអនុប្រធាននាយដ្ឋានចំនួន៨៨នាក់/ស្ត្រី១៩នាក់ (១៣)ប្រធានការិយាល័យចំនួន៦៥នាក់/ស្ត្រី២៦នាក់ (១៤)អនុប្រធានការិយាល័យចំនួន៨០នាក់/ស្ត្រី២៨នាក់ (១៥)មន្ត្រីចំនួន១៧១នាក់/ស្ត្រី៥៨នាក់ (១៦)ឧទ្ទកាល័យចំនួន ១៤នាក់/ ស្រី០៤នាក់។

ខ- <u>ការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រី</u>

| ល.រ | បរិយាយ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | មន្ត្រីផ្ទេរចូល | ០៥ | |
| ២ | មន្ត្រីផ្ទេរចេញ | ១១ | |
| ៣ | សម្រួលការកិច្ចជូនមន្ត្រីរាជការ | ០៣ | |
| ៤ | មន្ត្រីរាជការក្រសួងមុខងារសាធារណៈដែលបានដាក់ច្បាប់ឈប់សម្រាករយៈពេលខ្លី | ២៥ | |
| ៥ | ពិនិត្យនិងផ្តល់នីត្យានុកូលភាពស្តីពីការតែងតាំងនិងប្រគល់ភារកិច្ច | ២៩ | |
| ៦ | មន្ត្រីរាជការឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម | ០១ | |
| ៧ | ពិនិត្យសំណើសុំគោលការណ៍ស្តីពីការតែងតាំង | ៦ | |
| | សរុប | ៨០ | |

គ- <u>ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល</u>

- បានបញ្ជូនមន្ត្រីចំនួន៤៨៦នាក់/ស្ត្រី១៣៩នាក់ ទៅចូលរួមកម្មវិធីបណ្តុះបណ្តាលស្តីពី (១)Intermediate English Language and Communication Skills II ចំនួន០២លើក (២)Basic English Language and Communication Skill II (៣)Effective Note Taking and Project Proposal Writing (៤) មន្ត្រីរាជការក្របខណ្ឌថ្មីនៅសាលាភូមិន្ទរដ្ឋបាល និង សិក្ខាសាលាស្តីពីការកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ
- បានបញ្ជូនមន្ត្រីចំនួន២៦នាក់/ស្ត្រី៦នាក់ ចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស រួមមាន ប្រទេសអូស្ត្រាលី ប្រទេសឥណ្ឌា ប្រទេសឥណ្ឌូនេស៊ី ប្រទេសកូរ៉េខាងត្បូង ប្រទេសជប៉ុន ប្រទេសម៉ាឡេស៊ី ប្រទេសណូវែលហ្សេឡង់ ប្រទេសហ្វីលីពីន សិង្ហបុរី ស្រីលង្កា ប្រទេសថៃ និងបន្តថ្នាក់បណ្ឌិតនៅប្រទេសអង់គ្លេស។

១.៣- <u>ការងារនីតិកម្ម</u>

- បានរៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និង សំណើសុំកែសម្រួល បង្កើតថ្មី លុបចោលរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន១៥លើក និង ចូលរួមកិច្ចប្រជុំនានាចំនួន១០៣លើក
- បានធ្វើបទបង្ហាញច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅតាមក្រសួង ស្ថាប័ន និងអង្គភាពតាមបណ្តារាជធានី ខេត្តចំនួន២៥លើក

- បានឆ្លើយតបទៅនឹងការស្នើសុំផ្តល់យោបល់ ការកែសម្រួលរចនាសម្ព័ន្ធ និងបណ្តឹងរបស់ក្រសួង ស្ថាប័នចំនួន ១៤ រួមមាន (១)ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង ក្រសួងបរិស្ថាន ចំនួន៥ករណីក្នុងមួយក្រសួង (២) ក្រសួងសុខាភិបាល ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ និងខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី ចំនួន២ករណីក្នុងមួយក្រសួង/អង្គភាព និង (៣)ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងធម្មការនិងសាសនា ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អង្គភាពប្រឆាំងអំពើពុករលួយ ចំនួន១ករណីក្នុងមួយក្រសួង/អង្គភាព។

១.៤- <u>ការងារគ្រប់គ្រងក្របខណ្ឌ</u>

- បានឯកភាពលើសំណើសុំទិដ្ឋាការផ្លាស់ប្តូរបេក្ខជនជាប់បម្រុងចំនួន៣៩នាក់ ជំនួសបេក្ខជនជាប់ជាស្ថាពរដែលបានបោះបង់ចោលក្របខណ្ឌ
- ធ្វើលិខិតឆ្លើយតបចំពោះសំណើសុំរៀបចំប្រឡងផ្ទៃក្នុង ដើម្បីផ្លាស់ប្តូរប្រភេទក្របខណ្ឌជូនមន្ត្រីរាជការចំនួន ៩១៩កន្លែងរបស់ក្រសួងសុខាភិបាល
- បានឯកភាពលើសំណើសុំទទួលស្គាល់ក្របខណ្ឌអធិការអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ចំនួន៣១នាក់
- បានឯកភាពលើសំណើស្តីពីការសុំរក្សាទុកក្របខណ្ឌចំនួន២៤កន្លែ នៃផែនការក្របខណ្ឌ២០១៦ សម្រាប់បញ្ចូលបន្ថែមក្នុងផែនការក្របខណ្ឌឆ្នាំ២០១៧ របស់ក្រសួងធនធានទឹកនិងឧតុនិយម
- ធ្វើលិខិតស្នើសុំចុះត្រួតពិនិត្យចំពោះសំណើសុំប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាបន្ថែមចំនួន២០នាក់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ឆ្នាំ២០១៧
- បានរៀបចំការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌ៧ក្រសួង ស្ថាប័ន រួមមាន៖ ក្រសួងមុខងារសាធារណៈ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងទេសចរណ៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានធ្វើសំណើទៅប្រមុខរាជរដ្ឋាភិបាលសុំសេចក្តីសម្រេចលើករណីក្របខណ្ឌពិសេសចំនួន៦៩កន្លែង ដើម្បីជ្រើសរើសឱ្យចូលបម្រើការងារក្នុងក្របខណ្ឌៈ (១)ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន២៩កន្លែង សម្រាប់ឆ្នាំ២០១៧ និង (២)ក្រសួងរ៉ែនិងថាមពលចំនួន០៨កន្លែង (៣)ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន៣០កន្លែងនិង(៤)ទីស្តីការគណៈរដ្ឋមន្ត្រីចំនួន០២កន្លែង
- បានបដិសេធចំពោះសំណើសុំមន្ត្រីជាប់កិច្ចសន្យាបន្ថែមចំនួន០៥នាក់ ដើម្បីបង្គ្រប់តម្រូវការចាំបាច់នៅមូលដ្ឋានសុខាភិបាលទូទាំងខេត្តកែបសម្រាប់ឆ្នាំ២០១៨
- បានចាត់មន្ត្រីចំនួន៥១នាក់ ចូលរួមក្នុងគណៈកម្មាធិការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលគ្រប់ក្រសួង ស្ថាប័នក្នុងឆ្នាំ២០១៧
- បានផ្តល់ទិដ្ឋាការលើសំណើសុំ៖

| លរ | ក្រសួង-ស្ថាប័ន | ថ្នាក់ជាតិ | | | | ថ្នាក់ក្រោមជាតិ | | | | ទិដ្ឋាការ | | សរុបរួម | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ក | ខ | គ | សរុប | ក | ខ | គ | កិច្ចសន្យា | គ្រូកិច្ចសន្យា | | |
| ក្របខណ្ឌពិសេស | | | | | | | | | | | | | |
| ១ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ | ១ | | | ៩៥ | ៧៣ | ១២ | ១០ | | | ៩៦ | |
| ២ | រ៉ែនិងថាមពល | ៨ | ៨ | | | | | | | | | ៨ | |
| ៣ | សុខាភិបាល | ១ | ១ | | | ១ | | ១ | | | | ២ | |
| ៣.១ | អាជ្ញាធរប្រយុទ្ធប្រឆាំងជម្ងឺអេដស៍ | ១៩ | ១៦ | ៣ | | | | | | | | ១៩ | |
| ៤ | អប់រំ យុវជន និងកីឡា | ២៥ | ១៣ | ៤ | ៨ | ២២៣ | ៧១ | ៨៤ | ៦៨ | | | ២៤៨ | |
| ៥ | ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២៩៧ | ២៤៧ | ៥០ | | | | | | | | ២៩៧ | |
| ៥.១ | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | | | | | ១០ | ១០ | | | | | ១០ | |
| ៦ | បរិស្ថាន | ១ | ១ | | | | | | | | | ១ | |
| ៧ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១០២ | ៩៧ | ៥ | | | | | | | | ១០២ | |
| ៨ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣០ | ៣០ | | | | | | | | | ៣០ | |
| ៩ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ១០ | ១០ | | | | | | | | | ១០ | |

| លរ | ក្រសួង-ស្ថាប័ន | ថ្នាក់ជាតិ | | | | ថ្នាក់ក្រោមជាតិ | | | | ទិដ្ឋាការ | | សរុបរួម | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ក | ខ | គ | សរុប | ក | ខ | គ | កិច្ចសន្យា | គ្រូកិច្ចសន្យា | | |
| ១០ | ក្រសួងផែនការ | | | | | ៣១២ | ២៥១ | ៦១ | | | | ៣១២ | |
| ១០.១ | អគ្គនាយកដ្ឋានរដ្ឋបាលតុលាការ | ១៣៧ | ៩៧ | ២២ | ១៨ | | | | | | | ១៣៧ | |
| ១១ | ក្រសួងទេសចរណ៍ | ២ | ១ | | ២ | | | | | | | ២ | |
| ១២ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១ | ១ | | | | | | | | | ១ | |
| ១៣ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១២ | ១២ | | | | | | | | | ១២ | |
| ១៤ | ក្រសួងព័ត៌មាន | ១៥ | ១២ | ៣ | | | | | | | | ១៥ | |
| ១៥ | ក្រសួងមហាផ្ទៃ | | | | | ៤ | | ៤ | | | | ៤ | |
| ១៦ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ១ | | | | | | | | | ១ | |
| ១៧ | អង្គភាពប្រឆាំងអំពើពុករលួយ | ៩០ | ៥២ | ១១ | ២៧ | | | | | | | ៩០ | |
| | សរុប | ៧៥២ | ៦០០ | ៩៨ | ៥៤ | ៦៤៥ | ៤០៥ | ១៦២ | ៧៨ | | | ១៣៩៧ | |
| ក្របខណ្ឌថ្មី | | | | | | | | | | | | | |
| ១ | អប់រំ យុវជន និងកីឡា | ៥ | ៤ | | ១ | ២៣ | ២៣ | | | | | ២៨ | |
| ២ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២៤០ | ១២៦ | ១១៤ | | | | | | | | ២៤០ | |
| ៣ | ក្រសួងព័ត៌មាន | ៣៣ | ២៨ | ៥ | | ៣០ | ១៦ | ១៤ | | | | ៦៣ | |
| ៤ | ក្រសួងសុខាភិបាល | ១០ | ៦ | ៤ | | ៧០០ | ២៣៩ | ៤៦១ | | | | ៧១០ | |
| ៥ | ក្រសួងពាណិជ្ជកម្ម | ៦៥ | ៦៤ | ១ | | ២៩ | ២៤ | ៥ | | | | ៩៤ | |
| ៦ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ២៥ | ២៥ | | | | | | | | | ២៥ | |
| ៧ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ៧០ | ៦៩ | | ១ | ៧៩ | ៦១ | ៧ | ១១ | | | ១៤៩ | |
| ៨ | ក្រ.រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០ | ២០ | | | ៤២ | ៤២ | | | | | ៦២ | |
| ៩ | គណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម | ៥០ | ២៥ | ១០ | ១៥ | | | | | | | ៥០ | |
| ១០ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៦ | ៦ | | ២២ | ២២ | | | | | | ២៨ | |
| ១១ | ក្រ.ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១៦ | ១៦ | | | | | | | | | ១៦ | |
| ១២ | ក្រសួងបរិស្ថាន | ៤៦ | ៤៦ | | | | | | | | | ៤៦ | |
| ១៣ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ៣៤ | ២៧ | ៧ | | ៥៩ | ២៦ | ១៧ | ១៦ | | | ៩៣ | |
| ១៤ | ក្រសួងធម្មការនិងសាសនា | | | | | | | | | | | | |
| ១៤.១ | គ្រូពុទ្ធិកសិក្សាជាតិ | ៥០ | ១៥ | ១៤ | ២១ | | | | | | | ៥០ | |
| ១៥ | ក្រសួងកិច្ចការនារី | ៣៩ | ៣៨ | | ១ | | | | | | | ៣៩ | |
| ១៦ | ក្រសួងមុខងារសាធារណៈ | ២ | ២ | | | | | | | | | ២ | |
| ១៧ | ក្រសួងប្រៃសណីយ៍ | ៣៤ | ៣៣ | ១ | | ៤៤ | ២៧ | ១៧ | | | | ៧៨ | |
| ១៨ | ក្រសួងធនធានទឹកនិងឧតុនិយម | ៥២ | ៥២ | | | ៧៨ | ៧៨ | | | | | ១៣០ | |
| ១៩ | ក្រសួងកសិកម្មនិងរុក្ខាប្រមាញ់ | ៨៧ | ៨២ | ៥ | | ៦៨ | ៦៣ | ៥ | | | | ១៥៥ | |
| ២០ | ក្រសួងទេសចរណ៍ | ២២ | ២២ | | | ២៨ | ២៨ | | | | | ៥០ | |
| ២១ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ១៨ | ១៧ | ១ | | | | | | | | ១៨ | |
| | សរុប | ៩២៤ | ៧២៣ | ១៦២ | ៣៩ | ១២០២ | ៦៤៩ | ៥២៦ | ២៧ | | | ២១២៦ | |
| មន្ត្រីជាប់កិច្ចសន្យា | | | | | | | | | | | | | |
| ១ | ទីស្តីការគណៈរដ្ឋមន្ត្រី | | | | | | | | | ១១ | | ១១ | |
| ២ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | | | | | | | | | ១០២ | | ១០២ | |
| ៣ | ក្រសួងព័ត៌មាន | | | | | | | | | ៦ | | ៦ | |
| ៤ | ក្រសួងយុត្តិធម៌ | | | | | | | | | ៥៣ | | ៥៣ | |
| ៥ | ក្រសួងអប់រំ យុវជន និងកីឡា | | | | | | | | | ៧៥ | ៦៨៤ | ៧៥៩ | |
| ៦ | ក្រសួងមហាផ្ទៃ | | | | | | | | | ២០ | | ២០ | |
| | សរុប | | | | | | | | | ២៦៧ | ៦៨៤ | ៩៥១ | |
| សរុបរួម | | ១៦៧៦ | ១៣២៣ | ២៦០ | ៩៣ | ១៨៤៧ | ១០៥៤ | ៦៨៨ | ១០៥ | ២៦៧ | ៦៨៤ | ៤៤៧៤ | |

## ១.៥- ការងារត្រួតពិនិត្យរដ្ឋបាលនិងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

- បានធ្វើសំណើសុំសេចក្តីសម្រេចពីសម្តេចនាយករដ្ឋមន្ត្រីនិងផ្តល់ទិដ្ឋាការជូនក្រសួង ស្ថាប័ន ដូចខាងក្រោម៖

| ល.រ | បរិយាយ | សំណើសុំការសម្រេចពីសម្តេចនាយករដ្ឋមន្ត្រី | | ផ្តល់ទិដ្ឋាការជូនក្រសួងស្ថាប័ន | |
|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ១ | ផ្ទេរក្របខណ្ឌ | ៣០ | ៥ | ៥៥០ | ១០២ |
| ២ | តែងតាំង | ៣៩ | ១១ | ៣៦២ | ៩៣ |
| ៣ | តាំងស៊ប់ | ១០២៣៧ | ៤៧៦១ | ៣២៩៧ | ២១៣០ |
| ៤ | ចូលនិវត្តន៍តាមកាលកំណត់ | ៣៨៩ | ៩៧ | ២៥៦៥ | ៨៨២ |
| ៥ | ចូលនិវត្តន៍មុនតាមកាលកំណត់ | ៧ | | ៤៤ | ១០ |
| ៦ | លុបឈ្មោះ | ២ | | ២ | |
| ៧ | ដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ | ១៤៩២៦ | ២៩៦៩ | ២៦០៨៩ | ៩៨៧៤ |
| ៨ | ដំឡើងថ្នាក់ ឋានន្តរស័ក្តិតាមសញ្ញាបត្រ | ៨៧៥ | ១០៣ | ៥៣១១ | ១៦៩៧ |
| ៩ | រៀបប្រាក់បំណាច់មុខងារ | | | ១៨ | ១ |
| ១០ | ប្តូរប្រភេទក្របខណ្ឌ | ៣២៣ | ១១០ | | |
| ១១ | ស្ថិតនៅក្រៅក្របខណ្ឌដើម | ១ | | ៦ | ៣ |
| ១២ | ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | | | ២ | ១ |
| ១៣ | និយ័តថ្នាក់និងឋានន្តរស័ក្តិ | ១៩ | ២ | ៨៩ | ២៨ |
| ១៤ | រៀបបៀវត្សមូលដ្ឋាន | | | ១៨ | ២ |
| ១៥ | ចូលបម្រើការងារជាថ្មី | ១ | | ២ | |
| | សរុប | ២៦៨៤៩ | ៨០៥៨ | ៣៨៣៥៥ | ១៤៨២៣ |

- បានពិនិត្យ និង ផ្តល់ទិដ្ឋាការលើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល (ប្រាក់បៀវត្ស) នៃក្រសួង ស្ថាប័ន ដូចខាងក្រោម៖

| ល.រ | បរិយាយ | សរុប (នាក់) | ស្ត្រី (នាក់) |
|---|---|---|---|
| ១ | ជ្រើសរើសថ្មី | ៣៤៣៣ | ១៤៩៣ |
| ២ | តាំងស៊ប់ | ១១៤៧ | ៣២៦ |
| ៣ | តែងតាំង | ២៦៩១ | ៦៣៥ |
| ៤ | ផ្ទេរចូល | ៨៩១ | ២២៩ |
| ៥ | ចូលបម្រើការងារសារជាថ្មី | ៥៥៤ | ១៣៥ |
| ៦ | បញ្ចូលប្រាក់បំណាច់ថ្នាក់ដឹកនាំ | ៧៧៤ | ១២១ |
| ៧ | លាភការទីប្រឹក្សា | ២៩៩ | ៤១ |
| ៨ | លាភការជំនួយការ | ៨៤ | ៣៥ |
| ៩ | កែសម្រួលប្រាក់បំណាច់មុខងារ | ១០២៥ | ២៣៣ |
| ១០ | ដំឡើងថ្នាក់ ឋានន្តរស័ក្តិ | ១៩៨៣២ | ៣៩៦០ |
| ១១ | ដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ២១៧ | ៧៩ |
| ១២ | ដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម | ៧៩ | ២៣ |
| ១៣ | លុបឈ្មោះ | ២៧២ | ៧១ |
| ១៤ | បញ្ចប់មុខតំណែង | ១២ | ៣ |
| ១៥ | ផ្ទេរចេញ | ១៩៣៩ | ២២០ |
| ១៦ | ប្រាក់ឧបត្ថម្ភម្តងគត់ជូននិវត្តជន | ៣៩៩ | ១១០ |
| ១៧ | ចូលនិវត្តន៍ | ៤០៦ | ១០៥ |
| ១៨ | បន្ថែមកូន | ២០៤៨ | ៣០៥ |
| ១៩ | បន្ថយកូន | ១៣៣ | |
| ២០ | បន្ថែមប្រពន្ធ | ៧៥៤ | ៧៥៤ |
| ២១ | បន្ថយប្រពន្ធ | ១១ | ១១ |
| ២២ | ប្តូរប្រភេទក្របខ័ណ្ឌ | ១០៥ | ៤៣ |
| ២៣ | ប្រាក់ឧបត្ថម្ភតំបន់ជួបការលំបាក | ៩៩ | ៣០ |
| | សរុប | ៣៧២០៤ | ៨៩៦២ |

- បានពិនិត្យឃើញប្រាក់បៀវត្សដែលបានបើកលើសត្រូវបង្វែរចូលថវិការដ្ឋមានចំនួន ២.១៧៣.០៣៨.៨៤៩រៀល

- បានពិនិត្យ និង ផ្តល់ទិដ្ឋាការលើសលាកប័ត្រព័ត៌មានរបស់មន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័ន ដូចខាងក្រោម៖

| លរ | បរិយាយ | ក្របខណ្ឌ | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ក | ខ | គ | សរុប | ស្រី | |
| ១ | ប្រឡង | ៣២០៥ | ២១១២ | ១៣៣៣ | ៦៦៥០ | ២៦២៩ | |
| ២ | ជ្រើសរើសពិសេស | ៣៧៨ | ១៨៧ | ១១៣ | ៦៧៨ | ២៦៧ | |
| ៣ | ផ្ទេរចូល | ២០ | ១ | ២ | ២៣ | ២ | |
| | សរុប | ៣៦០៣ | ២៣០០ | ១៤៤៨ | ៧៣៥១ | ២៨៩៨ | |

១.៦- <u>ការងារគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានិងឯកសារមន្ត្រីរាជការស៊ីវិល</u>

- បានឆ្លើយតបនិងដោះស្រាយសំណួរតាមប្រព័ន្ធ Hot Line បានចំនួន៩៥៩ករណី
- បានរកឃើញប្រាក់បៀវត្សមិនប្រក្រតីចំនួន ៤.៨៣០.៧៤៨.២០០រៀល ដែលត្រូវបង្វែរចូលក្នុងថវិការដ្ឋវិញ
- បាន (១)បញ្ចូលទិន្នន័យមន្ត្រីរាជការស៊ីវិលក្នុងប្រព័ន្ធព័ត៌មានវិទ្យាចំនួន៨៥៤៩នាក់ (២)រៀបចំសលាកប័ត្រព័ត៌មានមន្ត្រីរាជការស៊ីវិលឡើងថ្មើរចំនួន១៣៦០៦នាក់ (៣)បញ្ចូលទិន្នន័យចលនាប្រែប្រួលស្តីពីតាំងសលាបត្រមន្ត្រីរាជការស៊ីវិលចំនួន៩០៥៣នាក់ (៤)ស្រាវជ្រាវសលាកប័ត្រព័ត៌មានរបស់មន្ត្រីរាជការស៊ីវិលតាមក្រសួង ស្ថាប័ននានា ដើម្បីផ្ទៀងផ្ទាត់ចំនួន១២០នាក់
- បានបោះពុម្ពតារាងទូទាត់បៀវត្សសម្រាប់ថ្នាក់កណ្តាលបានចំនួន៣២អង្គភាព និងសម្រាប់ថ្នាក់រាជធានីខេត្តបានចំនួន២៥អង្គភាព
- បានធ្វើការកែតម្រូវការប្រែប្រួលស្ថានភាពរបស់មន្ត្រីរាជការ ដូចខាងក្រោម៖

| ល.រ | បរិយាយ | ថ្នាក់កណ្តាល | ថ្នាក់រាជធានី ខេត្ត |
|---|---|---|---|
| ១ | មន្ត្រីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ២៨៦ | ៤៥០ |
| ២ | មន្ត្រីចូលបម្រើការងារវិញក្រោយពីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ៤០៤ | ៩២០ |
| ៣ | មន្ត្រីក្របខណ្ឌថ្មីបញ្ចូលក្នុងប្រព័ន្ធព័ត៌មាន | ៣១៧៣ | ៨៨១៤ |
| ៤ | មន្ត្រីក្របខណ្ឌថ្មីបញ្ចូលប្រាក់បៀវត្ស | ៣០៤៨ | ៦៧១៥ |
| ៥ | មន្ត្រីតាំងស៊ប់ | ៨៥៦ | ៤៩០៦ |
| ៦ | មន្ត្រីប្តូរក្របខណ្ឌ | ២៣២ | ១៥៧៨ |
| ៧ | មន្ត្រីតែងតាំង | ៣៩២១ | ៤៩៩០ |
| ៨ | មន្ត្រីទីប្រឹក្សា និង ជំនួយការ | ៣១០ | |
| ៩ | មន្ត្រីដល់អាយុចូលនិវត្តន៍ | ៧៤៧ | ២៨៥៣ |
| ១០ | មន្ត្រីលាឈប់ពីការងារ | ២៣២ | ៥៦៨ |
| ១១ | មន្ត្រីស្លាប់ | ៣៥ | ១២៦ |
| ១២ | មន្ត្រីឡើងថ្នាក់ប្រចាំឆ្នាំ | ១៦៩៧៤ | ១៣០១១៣ |
| ១៣ | មន្ត្រីឡើងឋានន្តរស័ក្តិ | ៥១៥ | |
| ១៤ | មន្ត្រីផ្ទេរចេញ | ១៩៧៧ | ២១៦៥ |
| ១៥ | មន្ត្រីផ្ទេរចូល | ៨៩៣ | ២៨៣៥ |
| ១៦ | មន្ត្រីសុំប្រាក់បំណាច់មុខងារ | ៤២៨ | ១០៦៩ |
| ១៧ | បញ្ចូលកូន | ១៩២១ | ១១៦៧៧ |
| ១៨ | បញ្ចូលប្រពន្ធ | ៦៣៧ | ២៤១៦ |
| ១៩ | មន្ត្រីប្តូរឋានន្តរស័ក្តិ | | ២៥៣ |
| ២០ | បញ្ចូលប្រាក់តំបន់ | | ១៧៨២៦ |
| ២១ | បញ្ចូលប្រាក់ពីរវេន គួប | | ១៤៦២៧ |
| | សរុប | ៣៩៥៨៩ | ២១៩៩០១ |

១.៧- <u>ការងារមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជានិងកិច្ចសហប្រតិបត្តិការអន្តរជាតិ</u>

- បានសម្របសម្រួលដើម្បីបញ្ជូនមន្ត្រីចំនួន២៩នាក់/ស្រី៩នាក់ ទៅចូលរួមវគ្គបណ្តុះបណ្តាលនៅ The Cambodia-Korea Cooperation Center, Cambodia-Singapore Training Center, សណ្ឋាគារភ្នំពេញ សណ្ឋាគារសុខាវីស៊ត ខេត្តសៀមរាប សណ្ឋាគារសុខាភ្នំពេញ សាលាភូមិន្ទរដ្ឋបាល

- បានរៀបចំឯកសារ និង សម្របសម្រួលពន្យាសុពលភាពលិខិតឆ្លងដែនផ្លូវការជូនមន្ត្រីចំនួន០៨នាក់និងធ្វើលិខិតឆ្លងដែនផ្លូវការជូនមន្ត្រីចំនួន២១នាក់
- បានរៀបចំសម្របសម្រួលដើម្បីបញ្ជូន (១)មន្ត្រីចំនួន០២នាក់ ទៅចូលរួមទស្សនកិច្ចសិក្សាស្តីពី "រដ្ឋបាលសាធារណៈ និងការគ្រប់គ្រងធនធានមនុស្ស (Public Administration and Human Resource Management)" ប្រទេសជប៉ុន និង (២)មន្ត្រីទៅចូលរួមកិច្ចប្រជុំនៅក្រៅប្រទេសចំនួន២៧នាក់/ស្ត្រីចំនួន២នាក់ និងនៅក្នុងប្រទេសចំនួន៦២នាក់/ស្ត្រី១២នាក់
- បានផ្តល់ធាតុចូលចំនួន៥០ករណី ដែលក្នុងនោះមានប្រទេស ហ្វីលីពីន សិង្ហបុរី ឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា ជប៉ុន ថៃ និងអគ្គលេខាធិការដ្ឋានអាស៊ាន ព្រមទាំងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានកែសម្រួលគម្រោងរបស់កម្ពុជាស្តីពី "គោលការណ៍ណែនាំអាស៊ាន ស្តីពីការផ្តល់សេវាសាធារណៈ" (ASEAN Guideline on Public Service delivery) ដែលស្ថិតនៅក្រោម ASEAN+3 Cooperation Fund និង ACCSM+3 Work Plan 2016-2020 ដាក់ជូនលេខាធិការដ្ឋានអាស៊ាន។

១.៨- <u>ការងារអគ្គាធិការដ្ឋាន</u>

- បានចុះអធិការកិច្ចមន្ត្រីមន្ទីរព័ត៌មានខេត្តប៉ៃលិន ដែលត្រូវបានលុបឈ្មោះចេញពីក្របខណ្ឌក្រសួងព័ត៌មាន
- បានចុះធ្វើអធិការកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរព័ត៌មាន និងមន្ត្រីរាជការសាលាខេត្តតាកែវ បាត់ដំបងនិងខេត្តស្ទឹងត្រែងដែលទទួលបៀវត្សពីរកន្លែងនិងបានរកឃើញទឹកប្រាក់ដែលបានបើកលើសចំនួន ៣៧.១៩០.៧៩០រៀល និងបានធ្វើរបាយការណ៍គោរពជូនឯកឧត្តមកិត្តិបណ្ឌិតរដ្ឋមន្ត្រី
- បានចុះអធិការកិច្ចលើការបង្វែរថវិកាចូលរដ្ឋវិញរបស់មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរបរិស្ថាន មន្ទីរព័ត៌មាន មន្ទីររ៉ែនិងថាមពល មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរឧស្សាហកម្ម និងសិប្បកម្ម មន្ទីរសុខាភិបាលចំណុះខេត្តកែប
- បានចុះធ្វើការត្រួតពិនិត្យលើការបែងចែកភារកិច្ចមន្ត្រីរាជការ ជាគ្រូបង្រៀនខ្មែរឥស្លាម (ក្របខណ្ឌពិសេស) នៅខេត្តប៉ៃលិននិងខេត្តព្រះវិហារបានធ្វើរបាយការណ៍គោរពជូនឯកឧត្តមកិត្តិបណ្ឌិតរដ្ឋមន្ត្រី
- បានចុះធ្វើការត្រួតពិនិត្យលើការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យានៅថ្នាក់ជាតិរួមមាន៖ ក្រសួងអប់រំ យុវជន និងកីឡា សាធារណការនិងដឹកជញ្ជូន ទេសចរណ៍ បរិស្ថាន ធនធានទឹកនិងឧតុនិយម ប្រៃសណីយ៍និងទូគមនាគមន៍ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សុខាភិបាល ព័ត៌មាន កិច្ចការនារី រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ យុត្តិធម៌ ផែនការ រ៉ែនិងថាមពល ធម្មការនិងសាសនា ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អភិវឌ្ឍន៍ជនបទ វប្បធម៌និងវិចិត្រសិល្បៈ ឧស្សាហកម្មនិងសិប្បកម្ម ពាណិជ្ជកម្ម និង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងនៅថ្នាក់ក្រោមជាតិរួមមាន៖ ខេត្តស្វាយរៀង កោះកុង ប៉ៃលិន មណ្ឌលគីរី រតនគីរី បន្ទាយមានជ័យ បាត់ដំបង កំពត ព្រះសីហនុ កំពង់ស្ពឺ ត្បូងឃ្មុំ កំពង់ឆ្នាំង កំពង់ចាម ព្រះវិហារ ស្ទឹងត្រែង កែប ឧត្តរមានជ័យ ក្រចេះ សៀមរាប ព្រៃវែង ពោធិ៍សាត់ និងកំពង់ធំ
- បានជួបប្រជុំពិភាក្សាជាមួយឯកឧត្តមអគ្គាធិការក្រសួងមហាផ្ទៃ ប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការនគរបាលជាតិនៅខេត្តកំពង់ស្ពឺ ដើម្បីដោះស្រាយលើបញ្ហាពាក់ព័ន្ធនិងមន្ត្រីរាជការដែលមានក្របខណ្ឌពីរកន្លែងដែលតម្រូវឱ្យសាមីខ្លួនបង្វែរថវិកាដែលបានបើកលើសចូលរតនាគារខេត្តវិញ។

១.៩- <u>ការងារសវនកម្មផ្ទៃក្នុង</u>

- បានចុះប្រមូលព័ត៌មាននិងធ្វើសវនកម្មនៅមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ព្រមទាំងបានរៀបចំរបាយការណ៍សង្ខេបនិងពេញលេញ បានចំនួន២៣មន្ទីរ គោរពជូនឯកឧត្តមកិត្តិបណ្ឌិតរដ្ឋមន្ត្រីជ្រាប
- បានចុះតាមដានការអនុវត្តអនុសាសន៍សវនកម្ម ព្រមទាំងបានរៀបចំរបាយការណ៍សង្ខេប ស្តីពីលទ្ធផលនៃការអនុវត្តអនុសាសន៍សវនកម្ម ទាំង១៩មន្ទីរ គោរពជូនឯកឧត្តមកិត្តិបណ្ឌិតរដ្ឋមន្ត្រីជ្រាប
- បានទទួលហត្ថលេខាគាំទ្រពីឯកឧត្តមកិត្តិបណ្ឌិតរដ្ឋមន្ត្រីចំពោះ (១)ការរៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងបីឆ្នាំ២០១៨-២០២០ ដើម្បីជូនដល់បណ្តាមន្ទីរ អង្គភាពចំណុះក្រសួងមុខងារសាធារណៈចូលរួមសហការ និងអនុវត្តលើផែនការយុទ្ធសាស្ត្រនេះ (២)ការរៀបចំសេចក្តីជូនដំណឹងសវនកម្ម ផែនការសវនកម្ម កម្មវិធីសវនកម្ម និងផែនការអនុវត្តសវនកម្មសម្រាប់ឆ្នាំ២០១៨

- បានធ្វើតារាង (Audit Check List for IAD-MCS) ទាក់ទងទៅនឹងការឆ្លើយកម្រងសំណួរត្រួតពិនិត្យស្ថានភាពមុខងារសវនកម្មផ្ទៃក្នុងនៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងមុខងារសាធារណៈ តាមការកំណត់របស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានធ្វើសេចក្តីណែនាំស្តីពីការបញ្ជូនឯកសារចុះប្រមូលព័ត៌មាន ការធ្វើសវនកម្ម និងការចុះតាមដានការអនុវត្តអនុសាសន៍សវនកម្មទៅនាយកដ្ឋាន អង្គភាព និងមន្ទីររាជធានី ខេត្ត
- ការបែងចែករៀបចំនិងត្រួតពិនិត្យរបាយការណ៍សវនកម្មសង្ខេប និង របាយការណ៍សវនកម្មពេញលេញ និងរបាយការណ៍តាមដានអនុវត្តអនុសាសន៍សវនកម្មប្រចាំត្រីមាសនីមួយៗឆ្នាំ២០១៧។

១.១០- <u>ការងារកែទម្រង់រដ្ឋបាលសាធារណៈ</u>

ក- <u>ការងារសេវាសាធារណៈ</u>

- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការវាយតម្លៃនិងផ្តល់រង្វាន់អង្គភាពផ្តល់សេវាសាធារណៈគំរូ
- បានរៀបចំសិក្ខាសាលាកម្រិតបច្ចេកទេសផ្ទៃក្នុងក្រសួង ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងដំបូង នៃច្បាប់ស្តីពីសេវាសាធារណៈនៅខេត្តមណ្ឌលគិរី
- បានរៀបចំប្រជុំបច្ចេកទេសចំនួន២លើក ដើម្បីពិនិត្យនិងពិភាក្សាលើការប្រមូលទិន្នន័យព័ត៌មានស្តីពីការផ្តល់សេវាសធារណៈរបស់ក្រសួង ស្ថាប័នគោលដៅចំនួន៧ ក្នុងការបង្កើតច្រកទ្វារអេឡិចត្រូចនិចផ្តល់ព័ត៌មានសេវាសាធារណៈ (Public Service Gateway)
- បានប្រមូលទិន្នន័យបឋមចំនួនសេវាសាធារណៈ ផ្តល់ដោយក្រសួង ស្ថាប័នគោលដៅចំនួន៧ ដែលគ្រោងនឹងរៀបចំបង្កើតច្រកទ្វារអេឡិចត្រូចនិចផ្តល់ព័ត៌មានសេវាសាធារណៈ (Public Service Gateway)
- បានរៀបចំនិងចុះអនុស្សរណៈយោគយល់គ្នារវាង អគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ និងអង្គការតម្លាភាពកម្ពុជា សម្រាប់គាំទ្រការរៀបចំការបង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរស័ព្ទស្តីអំពីសេវាសាធារណៈនិងការបង្កើតច្រកទ្វារអេឡិចត្រូនិចសម្រាប់សេវាសាធារណៈ
- បានជួបប្រជុំពិនិត្យនិងពិភាក្សាជាមួយអង្គការកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) និង លេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីជំរុញការអនុវត្តគម្រោងវិមជ្ឈការនិងរដ្ឋបាលសាធារណៈ (DAR Program)
- បានជួបប្រជុំពិភាក្សាជាមួយតំណាងធនាគារពិភពលោក (World Bank) ដើម្បីពិនិត្យនិងពិភាក្សាលើលទ្ធភាពគាំទ្រលទ្ធភាពក្នុងការកសាងច្បាប់ ស្តីពីសេវាសាធារណៈ និងគម្រោងកិច្ចសហប្រតិបត្តិការជាមួយក្រសួង មុខងារសាធារណៈ
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការទទួលព័ត៌មានត្រឡប់ និង ការតាមដានការអនុវត្តការងារដោយការប្រើប្រាស់ទូរស័ព្ទស្មាតហ្វូន (Beneficiary feedback and smart phone based performance monitoring) ដោយមានការសហការជាមួយធនាគារពិភពលោក (World Bank) រយៈពេល៥ថ្ងៃនៅក្រសួងមុខងារសាធារណៈ
- បានរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍ ស្តីពីការកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ ដែលសហការគាំទ្រដោយធនាគារពិភពលោក (World Bank)
- បានពិនិត្យលើដំណើរការទូរស័ព្ទទំនាក់ទំនងនៅក្នុងកម្រងព័ត៌មានសេវាសាធារណៈ និង វេបសាយរបស់ក្រសួង ស្ថាប័ន ក្នុងនោះក្រុមការងារបានរកឃើញលេខទូរស័ព្ទ១០ក្រសួង ស្ថាប័នដំណើរការ ១២ក្រសួង ស្ថាប័នដំណើរការតែមិនមានអ្នកទទួល និង ៤ក្រសួង ស្ថាប័នមិនដំណើរការ ដោយឡែកវេបសាយចំនួន ២៨ ក្រសួង ស្ថាប័នដំណើរការ លើកលែងតែក្រសួងយុត្តិធម៌ដែលមិនដំណើរការ
- បានធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានសេវាសាធារណៈរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិសរុបចំនួន១០សេវា
- បានបញ្ចូលកម្រងព័ត៌មានសេវាសាធារណៈ របស់ក្រសួងទេសចរណ៍ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សរុបចំនួន៨៦សេវាបន្ថែមទៀតទៅក្នុងកម្មវិធីការផ្តល់ព័ត៌មានសេវាសាធារណៈតាមទូរស័ព្ទស្មាតហ្វូន (Mobile App)

- បានចុះប្រមូលទិន្នន័យដើមគ្រា និង ពិភាក្សាលើរបាយការណ៍បឋម ស្តីពីការផ្ទេរការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធទៅថ្នាក់ក្រោមជាតិ នៅក្រុងស្រុកចំនួន៣ នៃខេត្តបាត់ដំបង
- បានចុះពិនិត្យនិងបិទបញ្ចប់របាយការណ៍និងផ្តល់អនុសាសន៍កែលម្អសេវាសាធារណៈ នៅមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តចំនួន៤ រួមមាន មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ កំពង់ចាម ខេត្តកោះកុងនិងខេត្តបាត់ដំបង ដោយផ្តោតលើសេវាចំនួន៣ រួមមាន (១)សេវាចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម (២)សេវាចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហៈធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ (៣)សេវាចេញលិខិតអនុញ្ញាតបិទស្លាកលើមុខទំនិញនិងសេវាកម្មរូបិយប័ណ្ណបរទេស។

ខ- <u>ការងារត្រួតពិនិត្យនិងវាយតម្លៃ</u>

- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការតាមដានត្រួតពិនិត្យ និង ការវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ជូនមន្ត្រីបង្គោលនៃក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅខេត្តចំនួន១២ ដែលមានសិក្ខាកាមសរុបចំនួន៥៥៦នាក់ (ស្រី៨២នាក់)
- បានរៀបចំសិក្ខាសាលាថ្នាក់តំបន់ចំនួន៤លើក ស្តីពីការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ ដែលសិក្ខាកាមសរុបចំនួន៥៥០នាក់ (ស្ត្រី៦៧នាក់)
- បានរៀបចំសិក្ខាសាលាបូកសរុបលទ្ធផលនៃក្រសួងមុខងារសាធារណៈ ស្តីពីវឌ្ឍនភាពការងារនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ រយៈពេលមួយអាណត្តិ (២០១៣-២០១៧) នៅខេត្តមណ្ឌលគិរី ដែលមានសិក្ខាកាមចូលរួមសរុប៩៨នាក់ (ស្រី១៨នាក់)
- បានរៀបចំត្រួតពិនិត្យនិងវិភាគទិន្នន័យលើចេនាសម្ព័ន្ធគ្រប់គ្រង ការពិពណ៌នាមុខតំណែង របស់ក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានរៀបចំនិងដាក់ចេញឯកសារពាក់ព័ន្ធទៅនឹងការបណ្តុះបណ្តាល ស្តីពីប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីប្រជុំជាមួយក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានរៀបចំប្រជុំគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីអនុម័តលើឯកសារចំនួន០៣ រួមមាន (១)របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៦ ស្តីពីការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (២) សកម្មភាពការងារអាទិភាពសម្រាប់ឆ្នាំ២០១៧ (៣)គោលការណ៍នៃការដាក់ឱ្យអនុវត្ត "ប្រព័ន្ធគ្រប់គ្រងគុណផល"
- បានរៀបចំតារាងផែនការសកម្មភាពសម្រាប់តាមដានការអនុវត្តការងារលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនិងវិស័យមុខងារសាធារណៈសរុបចំនួន៦៤លិខិតបទដ្ឋានគតិយុត្ត
- បានរៀបចំនិងដាក់កាលវិភាគ និង ប្រធានបទសម្រាប់បង្ហាញដល់និស្សិតដែលចុះកម្មសិក្សាក្នុងនាយកដ្ឋានត្រួតពិនិត្យនិង វាយតម្លៃ ក្នុងនោះប្រធានបទដែលផ្តោតសំខាន់រួមមាន (១)ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមុខងារសាធារណៈ (២)ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានត្រួតពិនិត្យនិងវាយតម្លៃ (៣)គោលនយោបាយសេវាសាធារណៈ (៤)គោលនយោបាយគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ (៥)ការកែទម្រង់ប្រព័ន្ធបៀវត្ស (៦)កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ (៧)ការងាររៀបចំលិខិតបទដ្ឋានគតិយុត្តនិងលិខិតរដ្ឋបាល។

គ- <u>ការងារអភិវឌ្ឍន៍ធនធានមនុស្ស</u>

- បានពិនិត្យនិងកែសម្រួលការពិពណ៌នាមុខតំណែងរបស់ក្រសួងស្ថាប័នផ្អែកតាមគោលការណ៍រួមនិងបទដ្ឋានគតិយុត្ត របស់ (១)ក្រសួងអប់រំ យុវជន និងកីឡា (២)ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ (៣)ក្រសួងធម្មការនិងសាសនា (៤)ក្រសួងធនធានទឹកនិងឧតុនិយម (៥)ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានពិនិត្យនិងផ្ទៀងផ្ទាត់លើឯកសារការកែសម្រួលការរៀបចំការពិពណ៌នាមុខតំណែងរបស់ក្រសួង ស្ថាប័នដែលបានផ្តល់មកចំនួន១៤ក្រសួង ស្ថាប័ន
- បានជំរុញ និងសហការជាមួយក្រសួង ស្ថាប័នចំនួន១២ ដែលមិនប្រគល់ឯកសារ ស្តីពីការរៀបចំការពិពណ៌នាមុខតំណែងរបស់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ

- បានរៀបចំសេចក្តីព្រាង (១)ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល (២)អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល និង (៣)អនុក្រឹត្យស្តីពីការរៀបចំពិពណ៌នាមុខតំណែង
- បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារទីភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ស្តីពី "ការត្រៀមដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល" និង ដាក់ឆ្លងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យនៃការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការរៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលដើម្បីពង្រឹងការគ្រប់គ្រងនិងការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការស៊ីវិលឱ្យកាន់តែមានសមត្ថភាព ភាពស្វាហាប់ ប្រសិទ្ធភាព និងការបញ្ជ្រាបទស្សនទាននៃការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល
- បានចូលរួមប្រជុំពិនិត្យនិងពិភាក្សាស្តីពី ADB's ២០១៧ Country Programming លើសេចក្តីព្រាងកម្មវិធីគម្រោងអភិវឌ្ឍន៍និងជំនួយបច្ចេកទេស ឆ្នាំ២០១៨-២០២០ ក្រោមក្របខណ្ឌហិរញ្ញប្បទាន ADB
- បានរៀបចំសិក្ខាសាលាស្តីពីកម្មវិធីចែករំលែកចំណេះដឹងនិងបទពិសោធន៍ពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ សម្រាប់ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រីក្រសួងមុខងារសាធារណៈ
- បានរៀបចំកិច្ចប្រជុំ ដើម្បីពិភាក្សាលើការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងត្រៀមរៀបចំការពិពណ៌នាមុខតំណែងវិជ្ជាជីវៈចំនួន១០លើក ដែលមានសមាសភាពចូលរួមពីគ្រប់ប្រធានក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជធានី ខេត្ត នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលារាជធានី ខេត្ត និងប្រធានមន្ទីរជំនាញជុំវិញរាជធានី ខេត្ត សរុបចំនួន៧៦៩នាក់
- បានចូលរួមប្រជុំ (១)ពិភាក្សាលើការរៀបចំផែនការយុទ្ធសាស្ត្រក្នុងការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល រវាងនាយកដ្ឋានគ្រប់គ្រងធនធានមនុស្សនិងស្ថាប័ន និង អង្គការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការអាឡឺម៉ង់ "GIZ" (២) ពិភាក្សាក្នុងក្របខណ្ឌកម្មវិធីកំណែទម្រង់ទាំងបីនិងពិគ្រោះយោបល់ស្តីពីការបណ្តុះបណ្តាលវគ្គខ្លី (៣)ពិនិត្យនិងពិភាក្សា លើសំណើសុំធ្វើការអង្កេតស្រាវជ្រាវ របស់អង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) និងធនាគារអភិវឌ្ឍន៍អាស៊ី (៤)ពិភាក្សាលើផែនការសកម្មភាពរួមនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ (៥)ពិភាក្សាលើវឌ្ឍនភាពការកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យធនធានមនុស្ស និងតារាងបៀវត្សរបស់មន្ត្រីរាជការនៃក្រសួងសុខាភិបាលតាមរយៈព័ត៌មានវិទ្យា និងទិសដៅបន្ត
- បានពិនិត្យនិងពិភាក្សាលើគម្រោងបណ្តុះបណ្តាលដែលគាំទ្រដោយ Civil Service College នៃប្រទេសសិង្ហបុរី។

ឃ- ការងារគោលនយោបាយលាភការនិងសមិទ្ធកម្ម និង ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស

- បានរៀបចំសេចក្តីព្រាង (១)អនុក្រឹត្យស្តីពីការកំណត់ប្រាក់បំណាច់មុខងាររបស់ប្រធាន អនុប្រធាន សមាជិក និងមន្ត្រីលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ហៅកាត់ថា គ.ជ.ប.ទ (២)ប្រកាសស្តីពីការបង្កើតការិយាល័យសោធន ការិយាល័យស្ថានីតិសម្បទានិងលេខាធិការដ្ឋាននៃបេឡាជាតិសន្តិសុខរបបសន្តិសុខសង្គម
- បានរៀបចំផែនការនិងចុះត្រួតពិនិត្យមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងសុខាភិបាលនៅទីស្តីការក្រសួងសុខាភិបាល មន្ទីរពេទ្យកាល់ម៉ែត វិទ្យាស្ថានប៉ាស្ទ័រ វិទ្យាស្ថានពិសោធន៍ឱសថ មន្ទីរពេទ្យគន្ធបុប្ផា មន្ទីរពេទ្យខ្មែរ-សូវៀត មន្ទីរពេទ្យព្រះកុសមៈ មជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្របូរាណ និងមន្ទីរពេទ្យព្រះអង្គឌួងនិងបណ្តាមន្ទីរសុខាភិបាល មណ្ឌលសុខភាពរាជធានី ខេត្ត
- បានចូលរួមប្រជុំ (១)ពិភាក្សាលើការរៀបចំគោលនយោបាយបៀវត្ស២០១៨-២០២៣ (២)ពិភាក្សាលើក្របខណ្ឌប្រចាំឆ្នាំ២០១៨ ដើម្បីកំណត់អំពីតម្រូវការក្របខណ្ឌថ្មីនិងមន្ត្រីកិច្ចសន្យា (៣)ពិភាក្សាលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានបញ្ចប់សេចក្តីព្រាង (១)អនុក្រឹត្យស្តីពីការកំណត់បៀវត្ស និង ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីរាជការបំពេញការងារនៅក្រៅប្រទេសនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ (២)អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន

- បានប្រជុំពិនិត្យនិងពិភាក្សាលើការរៀបចំប្រាក់បំណាច់មុខងារជូនថ្នាក់ដឹកនាំនៃក្រសួងព្រះបរមរាជវាំង
- បានរៀបចំប្រជុំ ដើម្បីពិភាក្សាលើ (១)ការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុ (២)ការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសាធារណៈរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (៣)ការរៀបចំប្រាក់បំណាច់មុខងារជូនមន្ត្រីអាជ្ញាសាលា (៤)ការរៀបចំដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិ មន្ត្រីអនុរក្សពន្ធនាគារ និងកងយោធពលខេមរភូមិន្ទ (៥)ការរៀបចំដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិលនិងមន្ត្រីថ្នាក់ក្រោមជាតិ (៦)ការធ្វើឱ្យមានសង្គតភាពលើការគណនារបបសន្តិសុខសង្គម (៧)ការពិនិត្យនិងផ្តល់ប្រាក់វិភាជន៍ជូនអតីតយុទ្ធជន (៨)ការបើកប្រាក់ឧបត្ថម្ភចំនួន០១លើកគត់ ជូនអតីតយុទ្ធជនដែលបានបាត់បង់ជីវិត (៩)លក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល (១០)ការកែសម្រួលប្រាក់ឧបត្ថម្ភប្រចាំខែ ចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក និង (១១)សំណើសុំបន្ថែមថវិកាជំពូក៦៤សម្រាប់ឧបត្ថម្ភរយៈពេល១២ខែដល់មន្ត្រីជាប់កិច្ចសន្យា៣៨នាក់បន្ថែមក្នុងឆ្នាំ២០១៧របស់ក្រសួងមុខងារសាធារណៈ
- បានជំរុញឱ្យអនុវត្តអនុក្រឹត្យ (១)ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសាធារណៈ (២)ស្តីពីការលើកលែងលក្ខខណ្ឌអាយុនិងការកំណត់អាយុបេក្ខជនចូលប្រឡងប្រជែងជ្រើសរើសចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល
- បានរៀបចំសេចក្តីព្រាងស្តីពីការបង្កើតក្រុមការងារកែទម្រង់បៀវត្សរបស់ក្រសួងមុខងារសាធារណៈ ដើម្បីសិក្សារចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។

ង- <u>ការងារសម្របសម្រួលការកែទម្រង់អន្តរវិស័យ</u>

- បានសម្របសម្រួលនិងចូលរួមកិច្ចប្រជុំលើកទី៣ របស់គណៈកម្មការគ្រប់គ្រងកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវដ្ឋបាល(EU-DAR)
- បានជួបរវាងគណៈប្រតិភូនៃវិទ្យាស្ថានបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិលនៃប្រទេសសិង្ហបុរីជាមួយថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ ដើម្បីពិភាក្សាលើការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំក្នុងការផ្តល់សេវាសាធារណៈ
- បានរៀបចំសូចនាករតាមដានរួមថ្មី (JMIS) ២០១៧-២០១៨ និង របាយការណ៍វឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួម ឆ្នាំ២០១៤-២០១៦ នៃក្រុមការងារបច្ចេកទេសកំណែទម្រង់រដ្ឋបាលសាធារណៈ
- បានសម្របសម្រួលរៀបចំកិច្ចប្រជុំ និង អនុម័តលើឯកសាររបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៦ រួមមាន (១)ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ និងសកម្មភាពអាទិភាពសម្រាប់ឆ្នាំ២០១៧ (២)គោលការណ៍នៃការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល (៣)របាយការណ៍ស្តីពីការសិក្សាលើមុខងារ រចនាសម្ព័ន្ធ និងនីតិវិធីនៃការបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានផ្ទៀងផ្ទាត់និងអង្កេតស្រាវជ្រាវលើប្រធានបទចំនួន០៣រួមមាន (១)ការបង្កើតសូចនាករដើម្បីគាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងវិស័យសាធារណៈ (២)រដ្ឋាភិបាលបើកចំហរនិងបើកចំហរទិន្នន័យសម្រាប់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ (៣)យុទ្ធសាស្ត្រនៃការគ្រប់គ្រងធនធានមនុស្សនៅក្នុងរដ្ឋបាលថ្នាក់ជាតិ នៅទីក្រុងសេអ៊ូលសាធារណៈរដ្ឋកូរ៉េ
- បានរៀបចំរបាយការណ៍ ស្តីពីលទ្ធផលនៃការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (SNDP)
- បានចូលរួមពិភាក្សា (១)ជាមួយតំណាងអង្គការកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) លើគម្រោងស្តីពី "ការកែទម្រង់វិមជ្ឈការនិងរដ្ឋបាលសាធារណៈ" និង "សកម្មភាពការងារបន្តគាំទ្រដោយ (GIZ) បន្ទាប់ពីប្រព័ន្ធគ្រប់គ្រងគុណផលត្រូវបានដាក់ឱ្យអនុវត្ត" (២)ជាមួយបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីភាពជាដៃគូសម្រាប់ប្រសិទ្ធភាពនៃការអភិវឌ្ឍ

- បានរៀបចំសិក្ខាសាលាថ្នាក់តំបន់ (១)ស្តីពីការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ (២)ស្តីពីវេទិកាកសាងសមត្ថភាពមុខងារសាធារណៈអាស៊ាន និងប្រព័ន្ធគ្រប់គ្រងគុណផល
- បានចូលរួមប្រជុំពិភាក្សាជាមួយប្រតិភូពីអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ដើម្បីពិភាក្សាការងារកែទម្រង់ប្រព័ន្ធបៀវត្សមន្ត្រីរាជការស៊ីវិលនិងចក្ខុវិស័យសម្រាប់ថ្ងៃអនាគត។

១.១១- ក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការ

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ បញ្ចប់ពីរខេត្តចុងក្រោយ គឺខេត្តព្រះវិហារ និង ខេត្តកំពង់ឆ្នាំង
- បានចុះសិក្សាពិគ្រោះយោបល់ ដើម្បីប្រមូលធាតុចូលពាក់ព័ន្ធនិងការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៥ខេត្ត គឺខេត្តព្រះវិហារ ឧត្តរមានជ័យ កំពង់ធំ បាត់ដំបង និងប៉ៃលិន
- បានរៀបចំសេចក្តីណែនាំស្តីពីបែបបទនិងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយសេចក្តីណែនាំស្តីពីបែបបទនិងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មឱ្យទៅគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ
- បានរៀបចំកែសម្រួលសេចក្តីណែនាំស្តីពីនីតិវិធីនៃការតែងតាំង និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

១.១២-ក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងនីតិវិធីផ្ទៃក្នុងនៃការអនុវត្តថវិកាតាមកម្មវិធីជូនថ្នាក់ដឹកនាំគ្រប់កម្រិត និងមន្ត្រីជំនាញហិរញ្ញវត្ថុនៃអង្គភាពថវិកាទាំង១៩បានចំនួន១វគ្គ
- បានរៀបចំឱ្យមានក្រុមការងារ ការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា FMIS និងបានចាត់បញ្ជូនសមាជិកនៃក្រុមការងារ FMIS ចំនួន៩នាក់ ដើម្បីចូលរួមការបណ្តុះបណ្តាលស្តីពីការរៀបចំនិងការអនុវត្តប្រព័ន្ធ FMIS នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានបូកសរុបរបាយការណ៍នៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣(MAP៣) ប្រចាំត្រីមាសទី១ ទី២ ទី៣ ទី៤ និងប្រចាំឆ្នាំ ហើយបានផ្ញើជូនអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុបានយ៉ាងទៀងទាត់និងទាន់ពេលវេលា។

១.១៣- ក្រុមការងារយេនឌ័រ

- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់អំពីការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមទៅក្នុងការរៀបចំផែនការអនុវត្តបីឆ្នាំ ដំណាក់កាលទី៣ (២០១៨-២០២០) ជាមួយក្រុមការងារនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានចូលរួមកិច្ចប្រជុំជាមួយក្រុមការងារអង្គការ UN WOMEN ដើម្បីពិនិត្យឡើងវិញលើសេចក្តីព្រាងគោលនយោបាយនិងយុទ្ធសាស្ត្រជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ
- បានចូលរួមកិច្ចប្រជុំវិសាមញ្ញនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីពិនិត្យលើខ្លឹមសាររបាយការណ៍បូកសរុបលទ្ធផលសកម្មភាពការងារឆ្នាំ២០១៦ និង លើកផែនការសកម្មភាពការងារឆ្នាំ២០១៧
- បានប្រជុំផ្ទៃក្នុងរៀបចំផែនការសកម្មភាពការងារនិងថវិកាសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៧ ដោយជំរុញអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨
- បានចូលរួមកិច្ចប្រជុំបូកសរុបការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីប្រចាំឆ្នាំ២០១៦ និង លើកទិសដៅផែនការសកម្មភាពឆ្នាំ២០១៧
- បានប្រជុំពិភាក្សាការងារជាមួយ (១)តំណាងអង្គការ UN WOMEN ដើម្បីត្រៀមលក្ខណៈអនុវត្តគម្រោង "ការលើកកម្ពស់ភាពជាតំណាងរបស់ស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យមុខងារសាធារណៈ" (២)តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីត្រៀមលក្ខណៈចុះនិងរៀបចំឧបករណ៍តាមដានវាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) អនុសាសន៍

របស់ប្រមុខរាជរដ្ឋាភិបាល និងច្បាប់ជាតិពាក់ព័ន្ធនឹងការលើកកម្ពស់ស្ថានភាព ជីវភាព ឋានៈ តួនាទី និងសុខុមាលភាពស្ត្រីនៅថ្នាក់ក្រោមជាតិ

- បានចូលរួមនិងសហការរៀបចំពិធីអបអរសាទរខួបលើកទី១០៦ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០១៧ ក្រោមប្រធានបទ "ស្ត្រីដើម្បីសុខសន្តិភាពនិងវឌ្ឍនភាព"ក្នុងគោលបំណងរំលេចពីតម្លៃនៃសន្តិភាពនិងការលើកកម្ពស់វប្បធម៌អហិង្សាដែលរាជរដ្ឋាភិបាលបាននឹងកំពុងគាំទ្រជំរុញឱ្យមានការចូលរួមពីគ្រប់ស្ថាប័នទាំងបុរស ទាំងស្ត្រីដើម្បីវឌ្ឍនភាពសង្គមនៅក្នុងប្រទេសកម្ពុជា
- បានចូលរួមជាមួយប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ចុះតាមដានវាយតម្លៃលើការអនុវត្តអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) អនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល និងច្បាប់ជាតិពាក់ព័ន្ធនឹងការលើកកម្ពស់ស្ថានភាព ជីវភាព ឋានៈ តួនាទី និងសុខុមាលភាពស្ត្រីនៅខេត្តកំពត។

១.១៤- <u>សាលាភូមិន្ទរដ្ឋបាល</u>

- បានជួសជុល និងស្ពានអាងទឹកខាងក្រោយសាលា លាបពណ៌ថ្នាំនៅបន្ទប់ទួលបាសាន្ត ផ្លាស់ប្តូរអំពូលភ្លើងតាមបន្ទប់ដែលខូច ដាក់អំពូលសូឡាបំភ្លឺនៅសួនច្បារខាងមុខដងទង់ជាតិ ធ្វើការជួសជុលទឹកនៅសហសាល និងធ្វើការផ្លាស់ប្តូរស្លាបព្រិលពីថ្មទៅដែកតាមទម្រង់លទ្ធកម្ម ព្រមទាំងបានដាំកូនឈើក្នុងបរិវេនសាលាភូមិន្ទរដ្ឋបាលចំនួន១០០ដើម និងបានរៀបចំជួសជុលបន្ទប់សិក្សា និង ផ្លាស់ប្តូរសម្ភារៈតាមបន្ទប់ការិយាល័យនិងបន្ទប់សិក្សាមួយចំនួន
- រៀបចំសម្របសម្រួលបំពេញពាក្យតាម Online និងការទទួលពាក្យប្រឡងប្រជែងសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១០ នៃសាលាភូមិន្ទរដ្ឋបាល ដែលមានចំនួនសរុប១៣០៥អង្គ/នាក់ នឹងទទួលពាក្យដែលបានបំពេញត្រឹមត្រូវតាមលក្ខណ្ឌរបស់សាលា បានចំនួន៨១៣អង្គ/នាក់ ស្រី២២៩នាក់
- សម្របសម្រួលកម្មវិធីបណ្តុះបណ្តាលដំបូងមន្ត្រីរាជការក្របខណ្ឌថ្មីឆ្នាំ២០១៦ វគ្គសិស្សមន្ត្រីក្រមការជំនាន់ទី៧ កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់-មធ្យមឆ្នាំ២០១៧ គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំ
- បានធ្វើការប្រឡងជ្រើសរើសសិស្សមន្ត្រីក្រមការជំនាន់ទី៧ រដ្ឋបាលបានលក់ពាក្យចំនួន ២១៧០ច្បាប់ ហើយទទួលបេក្ខជនដែលដាក់ពាក្យសរុបបានចំនួន១១០៥។

ក- <u>ការបណ្តុះបណ្តាលដំបូង</u>

ក.១- <u>សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៩</u>

- បានផ្ញើលិខិតទៅតាមក្រសួងស្ថាប័ន សំណើសុំផ្តល់ចំនួនតម្រូវការសិស្សមន្ត្រីជាន់ខ្ពស់ដែលក្រសួងស្ថាប័នត្រូវការសម្រាប់ឆ្នាំ២០១៨
- បានរៀបចំការប្រឡងប្រជែងសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១០ លើកទី១បេក្ខជនជាប់សរុបចំនួន១៨៨នាក់ លើកទី២បេក្ខជនជាប់សរុបចំនួន៧៥នាក់និងលើកទី៣ធ្វើតេស្តផ្ទាល់មាត់កំណត់យកត្រឹម៦០នាក់ (ជំនាញរដ្ឋបាលទូទៅ២០នាក់ សេដ្ឋកិច្ច-ហិរញ្ញវត្ថុ២០នាក់ និងជំនាញទំនាក់ទំនងអន្តរជាតិ២០នាក់)
- បានរៀបចំសេចក្តីសម្រេចស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីជាន់ខ្ពស់លើកទី១០របស់សាលាភូមិន្ទរដ្ឋបាល
- សម្រាប់៦ខែក្នុងដើមឆ្នាំ២០១៧ សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៩ ទាំង៥៦នាក់ បានបែងចែកជា៣ជំនាញ (ទំនាក់ទំនងអន្តរជាតិសាធារណៈ រដ្ឋបាលទូទៅ និងសេដ្ឋកិច្ចហិរញ្ញវត្ថុ) ជំនាញនីមួយៗមានមុខវិជ្ជាត្រូវសិក្សាចំនួន១០មុខដែលស្មើនិង២៥៥ម៉ោង
- បានរៀបចំចុះកម្មសិក្សារបស់មន្ត្រីជាន់ខ្ពស់ជំនាន់ទី៩ ទៅតាមក្រសួង ស្ថាប័នចំនួន១២ក្រសួងនិងខេត្តចំនួន០៣ សិស្សមន្ត្រីនឹងចុះកម្មសិក្សាចាប់ពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៧ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧
- បានរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនចំនួន០៦នាក់ចេញពីសិស្សមន្ត្រីជាន់ខ្ពស់សម្រាប់ចូលរួមកម្មវិធី UADC 2017 នៅខេត្តសៀមរាបនិងសេចក្តីសម្រេចស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីជាន់ខ្ពស់លើកទី១០។

ក.២- <u>សិស្សមន្ត្រីក្រមការជំនាន់ទី៧</u>

- បានរៀបចំសេចក្តីសម្រេចស្តីពីការទទួលស្គាល់បេក្ខជនអនុញ្ញាតឱ្យចូលប្រឡង ប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការលើកទី៧ ដែលមានបេក្ខជនសរុប១១០៥អង្គ/នាក់/ស្រី៣៨៥នាក់ ព្រះសង្ឃ៨៩អង្គ មន្ត្រីរាជការ២៥នាក់ និងមន្ត្រីយោធា១នាក់
- បានទទួលចុះកិច្ចសន្យាសិស្សមន្ត្រីក្រមការចំនួន១១៣នាក់ ចាប់ផ្តើមចូលរៀនហើយបែងចែកជា៣ក្រុម

- បានធ្វើលិខិតទៅតាមក្រសួង ស្ថាប័ន អំពីតម្រូវការកម្មសិក្សា និងបានរៀបចំកន្លែងចុះកម្មសិក្សារបស់សិស្សក្រមការជំនាន់ទី៧
- បានរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការជាលើកទី២ ទទួលបានបេក្ខជនជាប់ជាស្ថាពរចំនួន១២៤នាក់/ស្រី៣៥នាក់ និងព្រះសង្ឃ១១អង្គ ក្នុងនោះក៏មានបេក្ខជនបោះបង់ចំនួន១១នាក់/ស្រី១នាក់។

ក.៣- <u>មន្ត្រីរាជការក្របខណ្ឌថ្មី</u>

- បានរៀបចំធ្វើលិខិតផ្ញើទៅតាមក្រសួងស្ថាប័ន ដើម្បីសុំបញ្ជូនមន្ត្រី (ថ្នាក់ជាតិ) ក្របខណ្ឌថ្មី២០១៧ ចូលរួមទទួលការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាលនិងទទួលលិខិតឆ្លើយតបពីក្រសួងស្ថាប័នចំនួន២១
- បានធ្វើរបាយការណ៍បញ្ចប់ និង ផ្ញើវិញ្ញាបនបត្របញ្ជាក់ការសិក្សារបស់មន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មីឆ្នាំ២០១៦ (វគ្គ១ចំនួន ១៨៧នាក់ វគ្គ២ចំនួន ១៨៥នាក់ វគ្គ៣ចំនួន ១៨៦នាក់ វគ្គ៤ចំនួន ១៦០នាក់) ដែលបានបញ្ចប់ដោយជោគជ័យ និង រៀបចំលិខិតបញ្ជូនរួមជាមួយនឹងបញ្ជីឈ្មោះទៅតាមក្រសួង ស្ថាប័ន ដើម្បីចាត់បញ្ជូនចូលរួមវគ្គបណ្តុះបណ្តាលវគ្គទី៥បន្តជាកាតព្វកិច្ច។
- រៀបចំលិខិតទៅក្រសួងស្ថាប័ន ស្តីពីការចាត់បញ្ជូនមន្ត្រីរាជការក្របខណ្ឌថ្មី២០១៦ វគ្គ១ និងវគ្គ២ ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងដោយជោគជ័យ

ខ- <u>ការបណ្តុះបណ្តាលបន្ត (កម្មសិក្សាការីជាន់ខ្ពស់និងមធ្យម)</u>

- បានរៀបចំបញ្ចប់មុខវិជ្ជាសិក្សានៃវគ្គបណ្តុះបណ្តាលកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ និងមន្ត្រីមធ្យមឆ្នាំ២០១៦ ដោយជោគជ័យនៅពាក់កណ្តាលខែមីនា ឆ្នាំ២០១៧
- កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់និងមធ្យមតាមក្រុមនីមួយៗទាំង ៤៦ក្រុម បានឡើងការពារបញ្ចប់របាយការណ៍គ្រប់ក្រុមចប់ជាស្ថាពរ
- សាលាបានគ្រោងជ្រើសរើសកម្មសិក្សាការីចំនួន៣៧០នាក់ សម្រាប់វគ្គបណ្តុះបណ្តាលរយៈពេលវែងឆ្នាំ២០១៧នេះ ក្នុងនោះកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ចំនួន២៧០នាក់ និងមន្ត្រីមធ្យមចំនួន១០០នាក់
- បានបញ្ជូនលិខិតទៅគ្រប់គ្រងក្រសួង ស្ថាប័នស្នើសុំចាត់បញ្ជូនមន្ត្រីមកចូលរួមប្រឡងត្រួតពិនិត្យសមត្ថភាពដើម្បីចូលសិក្សាជាកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ ឬមន្ត្រីមធ្យមឆ្នាំ២០១៧
- បានសម្រេចគ្រោងបើកវគ្គខ្លីចំនួន៣វគ្គបណ្តុះបណ្តាល (១)សម្រាប់អភិបាលរងរាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ (២)សម្រាប់អគ្គនាយករងនិងប្រធាននាយកដ្ឋាននៃគ្រប់ក្រសួង ស្ថាប័ន និង(៣)សម្រាប់ប្រធានមន្ទីរនិងប្រធានអង្គភាពរាជធានី ខេត្ត
- កម្មវិធីសិក្សាឆ្នាំ២០១៧ សម្រាប់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ មានចំនួន២៤មុខវិជ្ជា ចំនួន៩០០ម៉ោង និងបាឋកថា ៤៥ម៉ោង និងមន្ត្រីមធ្យមចំនួន ២០មុខវិជ្ជា ចំនួន៥១៣ម៉ោង និងបាឋកថា ៣៦ម៉ោង ក្នុងរយៈពេល៩ខែ
- វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់កំពុងអនុវត្តបាន ១៩មុខវិជ្ជា ស្មើនឹង៦០៦ម៉ោងក្នុង១ថ្នាក់ បានបញ្ចប់១៤មុខវិជ្ជា និងចូលរួមស្តាប់បាឋកថា ១១លើក ស្មើនឹង៣៣ម៉ោង
- វគ្គវិក្រឹត្យការមន្ត្រីមធ្យមកំពុងអនុវត្តបាន ១៨មុខវិជ្ជា ស្មើនឹង៤៥ក្នុង១ថ្នាក់ បានបញ្ចប់១៤មុខវិជ្ជា និងចូលរួមស្តាប់បាឋកថាបានចំនួន១០លើក ស្មើនឹង៣០ម៉ោង
- វគ្គបណ្តុះបណ្តាលឆ្នាំ២០១៧នេះ មានកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ចំនួន៣០៣នាក់ ស្ត្រីចំនួន៤១នាក់ និងព្រះសង្ឃចំនួន១០អង្គ កម្មសិក្សាការីមន្ត្រីមធ្យមចំនួន១០៧នាក់ ស្ត្រី២០នាក់ និងព្រះសង្ឃចំនួន៣អង្គ ដោយឡែកកម្មសិក្សាការីចំនួន៦នាក់ ត្រូវបានអនុញ្ញាតឱ្យព្យួរការសិក្សាសម្រាប់ឆ្នាំ២០១៧ និងត្រូវអនុញ្ញាតជូនសម្រាប់ការចូលសិក្សាវិញនៅឆ្នាំ២០១៨។

គ- <u>ទំនាក់ទំនងអន្តរជាតិ</u>

គ.១- <u>សន្និសីទ សិក្ខាសាលា និងបឋកថា</u>

- សន្និសីទភាពជាអ្នកដឹកនាំ ស្តីពីការដឹកនាំជាយុទ្ធសាស្ត្រ ការអភិវឌ្ឍមូលធនមនុស្ស និងការប្រមើលមើលទៅថ្ងៃអនាគត នៅសាលាភូមិន្ទរដ្ឋបាល

- ចូលរួមសិក្ខាសាលាចំនួន០២លើក (១)ស្តីពីការកែលម្អគុណភាពនិងប្រសិទ្ធភាពសេវាសាធារណៈ (២)ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងនីតិវិធីនៃការអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិការបស់ក្រសួងមុខងារសាធារណៈ
- បាឋកថាស្តីពី(១) ការចែករំលែកបទពិសោធន៍ភាពជាអ្នកដឹកនាំ(២)ការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ(៣)យល់ដឹងពីស្ថានការណ៍ពិភពលោកបច្ចុប្បន្ន និងការរៀបចំនយោបាយការបរទេសរបស់កម្ពុជា(៤) ការអប់រំផ្លូវចិត្តក្នុងទ្រឹស្តីព្រះពុទ្ធសាសនា(៥)ការវិវត្តនៃច្បាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅកម្ពុជា(៦)កំណែទម្រង់វិស័យសាធារណការ និងដឹកជញ្ជូន(៧)កិច្ចគាំពារបរិស្ថាន(៨)កំណែទម្រង់វិស័យអប់រំនៅកម្ពុជា(៩)នយោបាយឈ្នះ ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ
- ចូលរួមរៀបចំសន្និសីទស្តីពី "វិធីសាស្ត្របណ្តុះបណ្តាលរបស់សហរដ្ឋអាមេរិកសម្រាប់មន្ត្រីរាជការទូតក្នុងតំបន់" ធ្វើបាឋកថាដោយលោកបណ្ឌិត Apichai W.Shipper សាស្ត្រាចារ្យរងនៃសាកលវិទ្យាល័យ Georgetown និងជាប្រធានតំបន់អាស៊ីនៃវិទ្យាស្ថានកិច្ចការបរទេសរបស់ក្រសួងការបរទេសអាមេរិក។

គ.២- <u>ទស្សនៈកិច្ចសិក្សានិងការចុះអនុស្សរណៈនៃការយោគយល់គ្នា</u>

- ធ្វើទស្សនកិច្ចសិក្សាសាលា INTAN ប្រទេសម៉ាឡេស៊ី ដើម្បីស្វែងយល់ពីការគ្រប់គ្រងសិស្ស មន្ត្រីសាលា សាស្ត្រាចារ្យ និងការអភិវឌ្ឍលើកម្មវិធីសិក្សា និងទស្សនកិច្ចសិក្សានៅប្រទេសថៃដើម្បីស្វែងយល់អំពីកម្មវិធីបណ្តុះបណ្តាល ការគ្រប់គ្រងស្ថាប័នអប់រំនិងការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអភិវឌ្ឍន៍រដ្ឋបាលនៃព្រះរាជាណាចក្រថៃ
- ជំនួបរវាងឯកឧត្តមនាយកសាលាភូមិន្ទរដ្ឋបាលនិងលោកសាស្ត្រាចារ្យ Ken Yotsumoto ព្រឹទ្ធបុរសនៃសាលាក្រោយឧត្តមសិក្សាសហប្រតិបត្តិការអន្តរជាតិ ដែលស្ថិតនៅក្នុងសាកលវិទ្យាល័យអន្តរជាតិកូបេ ប្រទេសជប៉ុនស្តីពី "ការសិក្សាប្រៀបធៀបការអប់រំច្បាប់នៅក្នុងគម្រោងបណ្តាប្រទេសនៅអាស៊ី ២០១៦-២០១៩"
- ទទួលគណៈប្រតិភូប្រទេសម៉ាឡេស៊ីដើម្បីចូលជួបពិភាក្សាការងារជាមួយឯកឧត្តមនាយកសាលាភូមិន្ទរដ្ឋបាល។

២- <u>អង្គភាពថ្នាក់ក្រោមជាតិ</u>

២.១- <u>ការប្រើប្រាស់ក្របខណ្ឌនិងឥណទានបៀវត្ស</u>

| ល.រ | រាជធានី-ខេត្ត | ចំនួនមន្ត្រី/បុគ្គលិក មន្ទីរ.ម.ស | | | ចំនួនមន្ត្រីខុទ្ទកាល័យ រាជធានី-ខេត្ត | | ប្រពន្ធ | កូន | ឥណទានបៀវត្ស | ចំនួនមន្ត្រីជាប់កិច្ចសន្យា | | ផ្សេងៗ[1] |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | ក្រសួង | សរុប | ស្រី | | | | សរុប | ស្រី | |
| ១ | ប.មានជ័យ | ១០ | ៣ | ៥ | ៨២០៣ | ៣៨៧៧ | ២៦៤៩ | ៧០១៣ | ៥៥៣៦៩៦៤៩៩០០ | ៥០៩ | ២០២ | ៨០៨២ |
| ២ | បាត់ដំបង | ១៧ | ៤ | ៥ | ១២៦៧៥ | ៦១៦០ | ៣៣៧៨ | ១១៣៥៧ | ១៤២០៧៨០៦៩០០ | ៧៥៧ | ៣៣៨ | ១៨៩១ |
| ៣ | កំពង់ចាម | ១៦ | ៧ | ៥ | ១០៣៨១ | ៥០១៥ | ៣១២៤ | ១១១៥៥ | ១១៣០៩៥៨៦៣០០ | ៦២១ | ២៥១ | |
| ៤ | កំពង់ឆ្នាំង | ១៤ | ៥ | ៥ | ៦៥០៧ | ២៦៩០ | ២១៥១ | ៦៣៦៤ | ៩០៨២៤៣៧៨៧៩០ | ៣៨៦ | ១៤២ | ៥៤៥៦ |
| ៥ | កំពង់ស្ពឺ | ១០ | ៤ | ៥ | ៧៦៥១ | ២៩២២ | ៣០០៩ | ៨០៨៨ | ១០៦៣០១៧១៦៤១០ | ៤៥៣ | ១៧១ | ៩៦៥៦ |
| ៦ | កំពង់ធំ | ១៧ | ៣ | ៥ | ៧៤៤០ | ៣២៩៩ | ២២៤៥ | ៧៥៦៥ | ៧៤២៨៥៧៩៨៤៤៨ | ៦១៤ | | ១៧៧៨៧ |
| ៧ | កំពត | ១៣ | | ៥ | ៨៤៦៩ | ៣៤៧៤ | ២៧៩១ | ៨២១៧ | ១១៥០១១៣៧១៣៦០ | ៤២៦ | ១៩០ | ១៧២៨៥ |
| ៨ | កណ្តាល | ១៣ | ៥ | ៥ | ១២១៦៨ | ៥៦២៥ | ៣៨២១ | ១២១៥៥ | ១៥៧៥២៧៥៥៣១០០ | ៧៨៥ | ២២៥ | ១៣៨០៨ |
| ៩ | កោះកុង | ១៧ | ៥ | ៥ | ២៤៩២ | ៨០៩ | ៧៥១ | ១៧២២ | ៣២៦០៩៤៦០២២៨ | ២៤៦ | ១២៦ | ១៨៣៩ |
| ១០ | ក្រចេះ | ២១ | ៩ | ៥ | ៤៧៧៣ | ២០៩៩ | ១០៨៩ | ៤១២៣ | ៦៤៨៣០៩០៩២១០ | ៣៨៣ | ១៧៩ | ៤៣៣៥ |
| ១១ | មណ្ឌលគិរី | ១១ | ៥ | ៥ | ១៩៦០ | ៧១៧ | ៤៣០ | ១០៨០ | ២៤៩២៧១៤៣៦០៧ | ២៥៣ | ១៣៦ | |
| ១២ | រាជធានីភ្នំពេញ | ២១ | ៧ | ៥ | ១៤៩៥៨ | ៧៦២២ | ៣៩៨៩ | ១២៩១០ | ១៩៤៨០៦០២០៦៦០ | ២៤២២ | ៤២៩ | ៦៦៣៩ |
| ១៣ | ព្រះវិហារ | ១៣ | ៥ | ៥ | ៣៨៩៩ | ១៥២៤ | ៩៤៦ | ២៤៦៨ | ៥៤៥៦១៦៨១៧៧៥ | ៣២៤ | ១២១ | ៤៦០១ |
| ១៤ | ព្រៃវែង | ១៥ | ៥ | ៥ | ១០៥៣៦ | ៤០៤៦ | ៤០០៨ | ១២៤៩៩ | ១៥៣៩៧២៣៨៨៥០០ | ៤១២ | ១៣៨ | ១០៦៣៥ |
| ១៥ | ពោធិ៍សាត់ | ១៤ | ៦ | ៥ | ៥៨០៣ | ២២៩៣ | ២០០២ | ៥៣០៣ | ៨២០៨៣៧៦២៨២០ | ៤៧៣ | ១៧៩ | ១០៨០៦ |

[1]ការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល

| ល.រ | រាជធានី-ខេត្ត | ចំនួនមន្ត្រី/បុគ្គលិក មន្ទីរ.ម.ស | | | ចំនួនមន្ត្រីទូទាំង រាជធានី-ខេត្ត | | ប្រពន្ធ | កូន | ឥណទានបៀវត្ស | ចំនួនមន្ត្រីជាប់ កិច្ចសន្យា | | ផ្សេងៗ[1] |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | កិច្ចសន្យា | សរុប | ស្រី | | | | | | |
| ១៦ | រតនគិរី | ១២ | | ៥ | ២៧៨៧ | ៩១៥ | ៨៥២ | ១៨៩២ | ៩១១៣៨២៩៨៥០ | ២២៥ | ៩៩ | ៣៣៥ |
| ១៧ | សៀមរាប | ២០ | ៥ | ៥ | ១០១២៧ | ៥០៩២ | ២៣០៩ | ៨១២២ | ១៣២៥៣១៣១០៩៧៨ | ៦៤៨ | | ៩៩៩៣ |
| ១៨ | ព្រះសីហនុ | ១៣ | ៤ | ៥ | ៣៤២០ | ១២៧១ | ១១២១ | ៣០៦៣ | ១០៩៩៧៣២១០៣៥៤ | ២២៤ | ៩៦ | ៣៩៩ |
| ១៩ | ស្ទឹងត្រែង | ១០ | ៣ | ៥ | ២៧៨២ | ១១៧៥ | ៦២៧ | ១៨៩១ | ៣៧៣៩២០៤១៦០០ | ៣៣២ | | ២៧ |
| ២០ | ស្វាយរៀង | ១២ | ៤ | ៥ | ៦៦៣៣ | ២១៨៨ | ៦៧០១ | ២៨១០ | ៨៧៣០៣១៣៥៧២៨ | ៥៦៣ | ១៨១ | ៤៩៣២ |
| ២១ | ត្បូងឃ្មុំ | ១២ | ៣ | ៥ | ៦៥៩៧ | ២៨៤២ | ១៧២១ | ៥៨២៥ | ៩៧២៦៦៤៧៤៧៤០ | ៤៩៣ | | |
| ២២ | តាកែវ | ១៥ | ៥ | ៥ | ១១២៦៧ | ៤២៩៦ | ៤៨៤៨ | ១៦២៤០ | ១៥៧៥៦៥១៤៣១២៨ | ៤៦២ | | ១០៩៧៨ |
| ២៣ | កែប | ១១ | ៣ | ៥ | ១៣១៥ | ៤៩៥ | ៣៤៧ | ១០២០ | ២០៦០៩១៩៦៥២០ | ២០៩ | | ២១៨៩ |
| ២៤ | ប៉ៃលិន | ១៤ | ៥ | ៥ | ១៦៥២ | ៦១២ | ៤៨៤ | ១១៧៦ | ២២៨១៨៨៦៦៨១ | ២៦១ | ១១៩ | ១៦៥៣ |
| ២៥ | ឧត្តរមានជ័យ | ៩ | ២ | ៥ | ៣០១៤ | ១០០០ | ៩៥១ | ២៣៩៤ | ៣៤៩៨៦៦០៤៨០ | ៣៩៩ | ១៩៣ | |
| | សរុប | ៣៣៥ | ១០៧ | ១២៥ | ១៥៩០៤០ | ៧១៦៥៨ | ៥៦៣៤៤ | ១៥៦៤៥២ | ១៨៩០១៦៣៧១៨០៦៧ | ១២១២៣ | ៣០៨៦ | ១៤៣៣២៦ |

២.២- បញ្ហាប្រឈមក្នុងការអនុវត្តដែនសមត្ថកិច្ចរបស់មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត

- បន្ទប់ធ្វើការតូចចង្អៀតនិងខ្វះមធ្យោបាយបំពេញការងារ (សម្ភារៈការិយាល័យ)
- មិនទាន់មានមន្ត្រី ដើម្បីបំពេញរចនាសម្ព័ន្ធមន្ទីរ តាមប្រកាសលេខ ១៩៧៩ មស.នក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
- សមត្ថភាពមន្ត្រីនៅមានកម្រិត និងខ្វះឯកសារពាក់ព័ន្ធនឹងគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ជាពិសេសមិនបានយល់ច្បាស់ពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- អង្គភាពមួយចំនួនយឺតយ៉ាវក្នុងការបញ្ជូនសំណុំឯកសារប្រាក់បៀវត្ស។

## III- **ទិសដៅការងារ**

បន្ថែមលើការអនុវត្តមុខងារ និង បេសកកម្មជាប្រចាំរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព ព្រមជាមួយការអនុវត្តបន្តដើម្បីពង្រឹងនិងពង្រីកនូវសមិទ្ធផលការងារដែលសម្រេចបានកន្លងមក ក្រសួងមុខងារសាធារណៈបានដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០១៨-២០២៣ ដូចខាងក្រោម៖

- រៀបចំអង្គវិជ្ជាជីវៈរបស់មន្ត្រីរាជការនិងការពិព័ណ៌នាមុខតំណែងក្នុងមុខងារសាធារណៈ ព្រមទាំងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ដើម្បីគាំទ្រការបំពេញការងាររបស់មន្ត្រីរាជការនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ
- រៀបចំច្បាប់ស្តីពីការផ្តល់សេវាសាធារណៈ និង លិខិតបទដ្ឋាននិងនីតិវិធីពាក់ព័ន្ធសម្រាប់អនុវត្តច្បាប់នេះ
- បង្កើនចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រី និង ស្ត្រីក្នុងមុខតំណែងគ្រប់គ្រង ដើម្បីជានាបង្កើនការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច
- បន្តពង្រឹងការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋតាមប្រព័ន្ធព័ត៌មានវិទ្យានិងធ្វើទំនើបកម្មវិស័យមុខងារសាធារណៈ ដើម្បីជានាប្រសិទ្ធភាព ផលិតភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈជូនមន្ត្រីរាជការ
- រៀបចំ និង ដាក់ឱ្យអនុវត្តឯកសារគោលនយោបាយបៀវត្សក្នុងវិស័យសាធារណៈ ឆ្នាំ២០១៨-២០២៣ ក្នុងគោលដៅបង្កើនប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗជូនដល់មន្ត្រីរាជការ ផ្អែកលើលទ្ធភាពនៃថវិកាជាតិនិងការទទួលស្គាល់និងការលើកកម្ពស់គុណផលរបស់មន្ត្រីរាជការនិងអង្គភាពផ្តល់សេវាសាធារណៈ
- ដឹកនាំ គ្រប់គ្រង និងដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ដោយផ្តោតលើការពង្រឹងគុណភាពនៃការផ្តល់សេវាសាធារណៈ ការពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនិងសមត្ថភាពស្ថាប័ន និង ការរៀបចំប្រព័ន្ធបៀវត្សដែលគាំទ្រផលិតភាពការងាររបស់មន្ត្រីរាជការនិងអង្គភាពផ្តល់សេវាសាធារណៈ

- បន្តពង្រឹងនិងពង្រីកការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ តាមរយៈពង្រីក និងពង្រឹងសមត្ថភាពរបស់សាលាភូមិន្ទរដ្ឋបាលនិងការបង្កើតវិទ្យាស្ថានមុខងារសាធារណៈភូមិភាគ
- បន្តអភិវឌ្ឍសមត្ថភាពធនធានមនុស្សនិងស្ថាប័នក្រោមផែនការការងារ ACCSM និង ACCSM+3 ២០១៦-២០២០ និង យន្តការនៃកិច្ចសហប្រតិបត្តិការអាស៊ាននិងទ្វេភាគី។

IV- **<u>សេចក្តីសន្និដ្ឋាន</u>**

ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ ក្រសួងមុខងារសាធារណៈ បានដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈនិងការកែទម្រង់រដ្ឋបាលសាធារណៈ សម្រេចបាននូវសមិទ្ធផលធំៗជាច្រើនស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា សមិទ្ធផលដ៏ធំធេងនេះ បង្កើតបានជាមូលដ្ឋានគ្រឹះ កសាងនូវជំនឿទុកចិត្តកាន់តែខ្លាំងឡើងរបស់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងសាធារណជន ចំពោះការដឹកនាំរបស់រាជរដ្ឋាភិបាល។

ផ្អែកលើគោលដៅជាយុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០១៨ ក្រសួងមុខងារសាធារណៈ នឹងខិតខំប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ក្នុងគោលបំណងកែលម្អវិស័យមុខងារសាធារណៈកម្ពុជាឱ្យឆ្លើយតបទៅនឹងការវិវត្តថ្មីៗនៃសង្គមជាតិនិងតំបន់។ ក្នុងន័យនេះ រដ្ឋបាលសាធារណៈកម្ពុជា នឹងត្រូវប្រែក្លាយឱ្យកាន់តែមានភាពរស់រវើក គុណភាព ភាពមានវិជ្ជាជីវៈ និងប្រសិទ្ធភាពក្នុងការបំពេញមុខងារ និង ភារកិច្ចរបស់ខ្លួន ដើម្បីបម្រើប្រជាពលរដ្ឋកាន់តែប្រសើរ។

ថ្ងៃ សុក្រ ៤រោច ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**